ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ២៣៧៤ ប្រក

# ប្រកាស
## ស្តីពី
## កិច្ចប្រជុំចូលកាន់តំណែង កិច្ចប្រជុំសាមញ្ញលើកទី១ និងកិច្ចប្រជុំសាមញ្ញលើកទី២ របស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងសេចក្ដីណែនាំលេខ ០២៤ សណន ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២៤ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងតាមការចាំបាច់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិនីមួយៗ ត្រូវរៀបចំកិច្ចប្រជុំចូលកាន់តំណែងក្នុងរយៈពេលមិនលើសពីដប់បួន(១៤)ថ្ងៃ បន្ទាប់ពីថ្ងៃដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ប្រកាសលទ្ធផលជាផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

ដំណើរការ នៃកិច្ចប្រជុំចូលកាន់តំណែង និងអធិបតី នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សានីមួយៗ នឹងកំណត់តាមលិខិតដោយឡែករបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ ២.-**

សមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលំដាប់លេខរៀងទី១ នៃបញ្ជីបេក្ខជនដែលទទួលបានសំឡេងគាំទ្រច្រើនជាងគេក្នុងក្រុមប្រឹក្សា ជាអ្នកផ្ញើលិខិតកោះអញ្ជើញសមាជិកក្រុមប្រឹក្សា ដែលជាប់ឆ្នោតក្នុងក្រុមប្រឹក្សារបស់ខ្លួន ឱ្យចូលរួមក្នុងកិច្ចប្រជុំចូលកាន់តំណែងតាមការកំណត់ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ។

សមាសភាពដែលត្រូវអញ្ជើញចូលរួមក្នុងកិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សានីមួយៗ មានក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

នាយករដ្ឋបាលសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើជាសេនាធិការជូនគណៈអភិបាលរបស់ខ្លួនក្នុងការសម្របសម្រួល និងចាត់ចែងរៀបចំកិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា។

**ប្រការ ៣.-**

កិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពមន្ត្រីជាន់ខ្ពស់មួយរូប ដែលចាត់តាំងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

កិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រសួងមហាផ្ទៃធ្វើប្រតិភូកម្ម និងប្រគល់សិទ្ធិជូនប្រធានក្រុមប្រឹក្សា និងអភិបាល អភិបាលរងរាជធានី ខេត្ត ដើម្បីធ្វើជាអធិបតី នៃកិច្ចប្រជុំចូលកាន់តំណែងក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ផ្អែកតាមការពិគ្រោះយោបល់ជាមួយប្រធានក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត អភិបាលរាជធានី ខេត្ត ត្រូវធ្វើការបែងចែកក្រុង ស្រុក ខណ្ឌ សម្រាប់ប្រធានក្រុមប្រឹក្សា អភិបាល អភិបាលរងរាជធានី ខេត្ត ធ្វើជាអធិបតីក្នុងកិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ដើម្បីធានាឱ្យកិច្ចប្រជុំចូលកាន់តំណែងខាងលើនេះ ដំណើរការតាមពេលវេលាដែលបានកំណត់ក្នុងប្រការ១ នៃប្រកាសនេះ អភិបាលរាជធានី ខេត្ត ត្រូវសហការសម្របសម្រួលជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ កំណត់កាលបរិច្ឆេទជាក់ស្តែងសម្រាប់រៀបចំកិច្ចប្រជុំចូលកាន់តំណែងក្រុមប្រឹក្សាតាមក្រុង ស្រុក ខណ្ឌនីមួយៗ រួចហើយត្រូវចម្លងមួយច្បាប់ជូនមកក្រសួងមហាផ្ទៃ។

**ប្រការ ៤.-**

អធិបតី នៃកិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវសម្របសម្រួលកិច្ចប្រជុំតាមកម្មវិធី ដូចមានចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ ៥.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវប្រជុំសាមញ្ញលើកទី១ មិនឱ្យហួសពីដប់ប្រាំ(១៥)ថ្ងៃ បន្ទាប់ពីថ្ងៃប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា។

ប្រធានក្រុមប្រឹក្សាត្រូវសម្របសម្រួលជាមួយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីកំណត់កាលបរិច្ឆេទ និងកោះអញ្ជើញសម្រាប់កិច្ចប្រជុំសាមញ្ញលើកទី១ របស់ខ្លួន។

កូរ៉ុមនៃកិច្ចប្រជុំសាមញ្ញលើកទី១ ត្រូវមានសមាជិកអញ្ជើញចូលរួមប្រជុំមិនតិចជាងពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូលគឺ៖

- ក្រុមប្រឹក្សាមានសមាជិក ២៧រូប ត្រូវមានសមាជិកយ៉ាងតិច ១៤រូប
- ក្រុមប្រឹក្សាមានសមាជិក ២៥រូប ត្រូវមានសមាជិកយ៉ាងតិច ១៣រូប
- ក្រុមប្រឹក្សាមានសមាជិក ២៣រូប ត្រូវមានសមាជិកយ៉ាងតិច ១២រូប

- ក្រុមប្រឹក្សាមានសមាជិក ២១រូប ត្រូវមានសមាជិកយ៉ាងតិច ១១រូប
- ក្រុមប្រឹក្សាមានសមាជិក ១៩រូប ត្រូវមានសមាជិកយ៉ាងតិច ១០រូប
- ក្រុមប្រឹក្សាមានសមាជិក ១៧រូប ត្រូវមានសមាជិកយ៉ាងតិច ០៩រូប
- ក្រុមប្រឹក្សាមានសមាជិក ១៥រូប ត្រូវមានសមាជិកយ៉ាងតិច ០៨រូប
- ក្រុមប្រឹក្សាមានសមាជិក ១៣រូប ត្រូវមានសមាជិកយ៉ាងតិច ០៧រូប
- ក្រុមប្រឹក្សាមានសមាជិក ១១រូប ត្រូវមានសមាជិកយ៉ាងតិច ០៦រូប។

**ប្រការ ៦.-**

ក្នុងកិច្ចប្រជុំសាមញ្ញលើកទី១ ក្រុមប្រឹក្សាត្រូវធ្វើការផ្សព្វផ្សាយ និងស្តាប់របាយការណ៍លើបញ្ហាដូចខាងក្រោម៖

**ទីមួយ៖** ការផ្សព្វផ្សាយអំពីសេចក្តីណែនាំលេខ.០២៤ សណន.របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា និងគំរូបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។ នាយករដ្ឋបាលសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវចាត់ចែងថតចម្លងឯកសារទាំងនេះ និងផ្តល់ជូនគ្រប់សមាជិកក្រុមប្រឹក្សាដោយភ្ជាប់ជាមួយលិខិតអញ្ជើញប្រជុំ។

**ទីពីរ៖** ការផ្តួចផ្តើមរៀបចំសេចក្តីព្រាងប្រតិទិន នៃកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាសម្រាប់រយៈពេលដប់ពីរ(១២)ខែ ចាប់ពីកិច្ចប្រជុំសាមញ្ញលើកទី២។

**ទីបី៖** អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍អំពីលទ្ធផលការងារ នៃរដ្ឋបាលរបស់ខ្លួន នៅក្នុងអាណត្តិដឹកនាំរបស់ក្រុមប្រឹក្សាអាណត្តិមុន និងការងារសេសសល់ ទិសដៅការងាររយៈពេល ០៣ខែ សម្រេចដោយក្រុមប្រឹក្សាផុតអាណត្តិ ហើយដែលត្រូវអនុវត្តបន្ត។

**ទីបួន៖** បញ្ហាផ្សេងៗ។

ក្រុមប្រឹក្សាមិនត្រូវអនុម័តបញ្ហាណាមួយ ក្នុងកិច្ចប្រជុំសាមញ្ញលើកទី១ នេះឡើយ។

**ប្រការ ៧.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំសាមញ្ញលើកទី២របស់ខ្លួន មិនឱ្យមុនម្ភៃប្រាំ(២៥)ថ្ងៃ ឬលើសពីសាមសិបប្រាំ(៣៥)ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកទី១ ឡើយ។

**ប្រការ ៨.-**

ក្នុងកិច្ចប្រជុំសាមញ្ញលើកទី២របស់ខ្លួន ក្រុមប្រឹក្សាត្រូវអនុម័តឱ្យបាននូវឯកសារដូចខាងក្រោម៖

- កំណត់ហេតុកិច្ចប្រជុំលើកទី១
- ដីកាស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន
- ប្រតិទិននៃកិច្ចប្រជុំសាមញ្ញសម្រាប់រយៈពេលដប់ពីរ(១២)ខែ រាប់ចាប់ពីកិច្ចប្រជុំលើកទី២ នេះទៅ។

**ប្រការ ៩.-**

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលបានអនុម័តរួចហើយ ត្រូវចម្លង ០១ច្បាប់ រួចផ្ញើមកក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងយូរប្រាំ(០៥)ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃចុះហត្ថលេខាលើដីកា។

**ប្រការ ១០.-**

ដើម្បីធានាដល់ការចាប់ផ្តើមបំពេញការងាររបស់ក្រុមប្រឹក្សា បន្ទាប់ពីការប្រកាសចូលកាន់តំណែងរបស់ក្រុមប្រឹក្សា អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យនាយករដ្ឋបាល ដោយមានទីចាត់ការ ឬការិយាល័យពាក់ព័ន្ធ ជាសេនាធិការរៀបចំកិច្ចការមួយចំនួនដូចដែលធ្លាប់បានអនុវត្តសម្រាប់ក្រុមប្រឹក្សាអាណត្តិទី៣កន្លងមក មានជាអាទិ៍៖

- រៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំឱ្យដល់អ្នកដែលត្រូវអញ្ជើញចូលរួមប្រជុំ
- រៀបចំទីកន្លែងប្រជុំ
- រៀបចំសេចក្តីព្រាងកំណត់ហេតុ នៃកិច្ចប្រជុំក្រុមប្រឹក្សា ដើម្បីពិនិត្យ និងអនុម័ត
- រៀបចំតាក់តែងឯកសារនានា តាមតម្រូវការរបស់ក្រុមប្រឹក្សា
- ទុកដាក់ឯកសារនានា របស់ក្រុមប្រឹក្សា។

**ប្រការ ១១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១២.-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ ប្រធានអង្គភាពពាក់ព័ន្ធនានាចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ដូចប្រការ ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## សមាសភាពភ្ញៀវ ដែលត្រូវអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ
## ចូលកាន់តំណែងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

| ល.រ | សមាសភាពភ្ញៀវអញ្ជើញចូលរួម | ក្រុមប្រឹក្សា | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | រាជធានី | ខេត្ត | ក្រុង | ស្រុក | ខណ្ឌ | |
| ១ | អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងមុខតំណែង | X | X | X | X | X | |
| ២ | ប្រធានមន្ទីរ អង្គភាពជំនាញនៃក្រសួង ស្ថាប័ននានា ដែលប្រចាំនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | X | X | X | X | X | |
| ៣ | មេឃុំ ចៅសង្កាត់ | X | O | X | X | X | |
| ៤ | ប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ប្រចាំរាជធានី ខេត្ត | X | X | O | O | O | |
| ៥ | ប្រធានអង្គភាពកងយោធពលខេមរភូមិន្ទ នគរបាល កងរាជអាវុធហត្ថប្រចាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | X | X | X | X | X | |
| ៦ | តំណាងសភាពាណិជ្ជកម្មរាជធានី ខេត្ត | X | X | O | O | O | |
| ៧ | តំណាងអង្គការជាតិ និងអន្តរជាតិដែលមានក្នុង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមការចាំបាច់ | X | X | X | X | X | |
| ៨ | តំណាងគណបក្សដែលមានអាសនៈក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | X | X | X | X | X | |

<u>**កំណត់សម្គាល់ ៖**</u>

- សញ្ញា " X " ជាសញ្ញាដែលត្រូវអញ្ជើញចូលរួមប្រជុំ
- សញ្ញា " o " ជាសញ្ញាបញ្ជាក់មិនបាច់អញ្ជើញចូលរួមប្រជុំ។

# ឧបសម្ព័ន្ធទី២

## *កម្មវិធី*

## *ប្រជុំចូលកាន់តំណែងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*

១- ចុះបញ្ជីវត្តមានសម្រាប់តែសមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោត ដែលបានអញ្ជើញចូលរួមប្រជុំកាន់តំណែង

២- គណៈចាត់តាំងកម្មវិធីប្រកាសកម្មវិធី និងជម្រាបជូនអំពីគណៈអធិបតី ភ្ញៀវកិត្តិយសអញ្ជើញចូលរួម

៣- គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា

៣- សុន្ទរកថាស្វាគមន៍ និងរបាយការណ៍សង្ខេបរបស់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

៤- អានព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

( ក្នុងពេលអានឈ្មោះសមាជិកណាម្នាក់ សមាជិកនោះត្រូវក្រោកឈរដើម្បីបង្ហាញខ្លួនដល់អង្គពិធី )

៥- ពិធីប្រគល់ព្រះរាជក្រឹត្យ ឬអនុក្រឹត្យស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

៦- មតិចាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាអាណត្តិថ្មី ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន

៧- មតិផ្តាំផ្ញើរបស់អធិបតីនៃអង្គប្រជុំ

៨- គោរពភ្លេងជាតិ បិទកម្មវិធី។